# មតិយោបល់របស់អង្គការសង្គមស៊ីវិល
# លើសេចក្តីព្រាង«ក្រមធនធានធម្មជាតិនិងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា»

តាមរយៈសេរីនៃមតិយោបល់ និងអនុសាសន៍របស់អង្គការសង្គមស៊ីវិល ដែលបានផ្តល់ជូនក្រសួងបរិស្ថាន និងក្រុមអ្នកច្បាប់វិស្ណុរ នាពេលកន្លងមក និងលទ្ធផលនៃសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិរបស់អង្គការសង្គមស៊ីវិលលើសេចក្តីព្រាង«ក្រមធនធានធម្មជាតិនិងបរិស្ថាននៃព្រះរាជាណាចក្រកម្ពុជា» នៅភោជនីយដ្ឋានទន្លេបាសាក់២ នាថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦។ យើងខ្ញុំជាអង្គការសង្គមស៊ីវិល រួមមានអង្គការជាតិ/អន្តរជាតិ អ្នកស្រាវជ្រាវ សាស្ត្រាចារ្យ អ្នកច្បាប់ អនុក្រុមការងារបច្ចេកទេសនៃក្រមធនធានធម្មជាតិនិងបរិស្ថាន ក្រុមការងារអង្គការសង្គមស៊ីវិលស្តីពីក្រមធនធានធម្មជាតិនិងបរិស្ថាន និង តំណាងសហគមន៍ជនជាតិដើមភាគតិច (ដូចមានឈ្មោះក្នុងឯកសារដែលបានភ្ជាប់ជូន) សូមស្នើឲ្យមានការបញ្ចូលនូវមតិយោបល់ជារួមរបស់យើងខ្ញុំ ទៅក្នុងសេចក្តីព្រាងចុងក្រោយនៃក្រមធនធានធម្មជាតិនិងបរិស្ថាន នៃព្រះរាជាណាចក្រកម្ពុជា[1] ដែលមានខ្លឹមសារ ដូចតទៅ៖

១. បញ្ចូល**ការទទួលខុសត្រូវខ្ពស់ និង ដែនសមត្ថកិច្ចជាក់លាក់ពីស្ថាប័នរាជរដ្ឋាភិបាលនៃក្រសួងពាក់ព័ន្ធ** ដើម្បីផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋ ក៏ដូចជាសហគមន៍ ក្នុងការទំនាក់ទំនង ក៏ដូចជាចូលរួមជាមួយរាជរដ្ឋាភិបាលប្រកបដោយតម្លាភាព និង គណនេយ្យភាព ក្នុងការអនុវត្តន៍ក្រមដើម្បីការពារធនធានធម្មជាតិ និង បរិស្ថាន របស់ព្រះរាជាណាចក្រកម្ពុជា។ ឧទាហរណ៍ដូចជា ក្នុងគន្ថីទី ១ មាតិកាទី ២៖ ការរៀបចំនូវស្ថាប័នមានសមត្ថកិច្ច/បញ្ហាសមត្ថកិច្ច គឺគប្បីពិនិត្យនិច័យឲ្យច្បាស់លើភាពត្រួតស៊ីគ្នានៃដែនសមត្ថកិច្ចរបស់ក្រសួងពាក់ព័ន្ធនីមួយៗ។ ករណីដែនសមត្ថកិច្ចរបស់ក្រសួងធនធានទឹក និងឧតុនិយម ក្នុងការបង្កើតអនុក្រិត ដើម្បីគ្រប់គ្រងការបង្ហូរទឹក ឬសារធាតុបំពុលចូលទៅក្នុងដែនទឹករបស់ប្រទេសកម្ពុជា។ ដែនសមត្ថកិច្ចនេះអាចនឹងបង្កើតឱ្យមានជម្លោះជាមួយនឹងសិទ្ធិអំណាចនៃក្រសួងបរិស្ថានដែលមានស្រាប់ក្នុងការចេញលិខិតអនុញ្ញាតសម្រាប់ កម្រិតបរិមាណនៃការបង្ហូរទឹក ឬសារធាតុបំពុលចូលទៅក្នុងដែនទឹក ដែលស្ថិតក្រោមផ្នែកមួយស្តីពីការត្រួតពិនិត្យការបំពុលទឹក។

២. **ការចូលរួមជាសាធារណៈ**ប្រកបដោយអត្ថន័យក្នុងដំណើរការធ្វើការសម្រេចចិត្ត **គឺចាំបាច់ត្រូវពិចារណាដាក់បញ្ចូលក្នុងក្រមនេះ**ដើម្បីធានាថា គម្រោងអភិវឌ្ឍន៍នីមួយៗគឺមិនប៉ះពាល់ធ្ងន់ធ្ងរដល់ សុខភាពរបស់មនុស្ស ធនធានធម្មជាតិ និង បរិស្ថានជុំវិញ។ ក្រមគួរតែធានាឱ្យបាននូវវិសាលភាពធំបំផុតដែលអាចធ្វើបាន ដែលភាគីពាក់ព័ន្ធទាំងអស់ត្រូវបានផ្តល់ឱកាសដើម្បីចូលរួមចំណែកក្នុងការធ្វើសេចក្តីសម្រេចក្នុងដំណើរការអភិវឌ្ឍន៍គម្រោង។ នេះគួរតែរួមបញ្ចូលទាំង ដំណាក់កាលនៃការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ការវាយតំលៃបរិស្ថានជាយុទ្ធសាស្ត្រ ការអនុញ្ញាត និងការចេញអាជ្ញាប័ណ្ណដោយក្រសួងពាក់ព័ន្ធ និងការអភិវឌ្ឍនៃផែនការ ការប្រើប្រាស់ធនធានធម្មជាតិ ជាដើម ។ល។ ការចូលរួមជាសាធារណៈដែលស្ថិតក្នុងកម្រិតអប្បបរមានោះ គឺតម្រូវឱ្យមាន៖ (1) សេចក្តីជូនដំណឹងជាសាធារណៈនៃ

---

[1] ចំពោះមតិយោបល់លំអិត សូមមើលក្នុង «មតិយោបល់ដែលបានផ្ញើជូនកាលពីថ្ងៃទី ២០ កញ្ញា ឆ្នាំ ២០១៦ និងថ្ងៃទី ៣១ តុលា ឆ្នាំ ២០១៦» ដែលផ្ញើជូន ក្រសួងបរិស្ថាន និង ក្រុមមេធាវីវិស្ណុ។

ការធ្វើដំណើរការនៃសេចក្តីសម្រេចចិត្តផ្នែកបរិស្ថាន; (2) ការដឹងពីព័ត៌មាន និងទិន្នន័យអំពីការសម្រេចចិត្តដើម្បីលើកយកមកពិចារណា និង (3) ផ្តល់ពេលវេលាគ្រប់គ្រាន់សម្រាប់ភាគីពាក់ព័ន្ធ ត្រួតពិនិត្យព័ត៌មាន និងទិន្នន័យ ក៏ដូចជាផ្តល់យោបល់។ ទាក់ទងទៅនឹងគម្រោងអភិវឌ្ឍន៍ខ្នាតធំ ដែលអាចមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើសុខភាពមនុស្ស ឬបរិស្ថាន ក្រមគួរតែធានាថាអ្នកស្នើគម្រោង ឬក្រសួងពាក់ព័ន្ធ ត្រូវធ្វើវេទិកាសាធារណៈដើម្បីផ្សព្វផ្សាយអំពីគម្រោង ឬផែនការ និងផលប៉ះពាល់សក្តានុពលរបស់គម្រោង ហើយត្រូវផ្តល់ចម្លើយតបទៅដល់សាធារណៈជនវិញ ថាតើ ហេតុអ្វី កង្វល់ ឬមតិយោបល់របស់ពួកគេ គឺមិនត្រូវបានយកមកពិចារណាដើម្បីបញ្ចូលក្នុងការសម្រេចចិត្តចុងក្រោយនៃការអភិវឌ្ឍន៍គម្រោង។

៣. ស្នើឲ្យបញ្ចូល សិទ្ធិ **«ស្វ័យសម្រេច»** និង **«ការអនុវត្តន៍តាមបែបវិមជ្ឈការ និង សហវិមជ្ឈការ»** ចំពោះការបែងចែកថវិកាពីថ្នាក់ជាតិ ទៅ ថ្នាក់ក្រោមជាតិ ទាក់ទងនឹងការងារគ្រប់គ្រង ការពារបរិស្ថាននៅថ្នាក់មូលដ្ឋានផ្ទាល់។ ឧទាហរណ៍ ការផ្តល់សិទ្ធិដល់ សហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍តំបន់ព្រៃការពារ សហគមន៍ទេសចរណ៍ធម្មជាតិ សហគមន៍គ្រប់គ្រងធនធានធម្មជាតិ (CBNRM) សហគមន៍កសិករកសិកម្មខ្មែរ សហគមន៍គ្រប់គ្រងគ្រោះមហន្តរាយ (CBDRM) សហគមន៍កសិករប្រើប្រាស់ទឹក ។ល។ ដើម្បីធ្វើការសម្រេចចិត្តប្រើប្រាស់ថវិកាថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រងធនធានធម្មជាតិ និង បរិស្ថានដោយខ្លួនឯង។ ឧទាហរណ៍ ទាក់ទងនឹងការគ្រប់គ្រងសត្វព្រៃ បើសិនជាមានការដាក់ពាក្យស្នើសុំបរបាញ់គួរគប្បីត្រូវឆ្លងតាមអាជ្ញាធរឃុំផងដែរ។

៤. ទាក់ទងនឹង **កិច្ចការពារ អភិរក្ស និងគ្រប់គ្រងសត្វព្រៃ** តើកសិដ្ឋានសត្វព្រៃទ្រង់ទ្រាយបែបណាដែលក្រសួងបរិស្ថានអនុញ្ញាតអោយបង្កើតឡើង? តើក្រសួងបរិស្ថានគួរបង្កើតអោយមានជាវិទ្យាស្ថាន រឺមជ្ឈមណ្ឌលស្រាវជ្រាវ តាមដាន ត្រួតពិនិត្យ សុខភាពសត្វព្រៃ និងការបង្កាត់ពូជសត្វព្រៃឬទេ? តើការបរបាញ់សត្វព្រៃទ្រង់ទ្រាយបែបណាដែលទទួលបានលិខិតអនុញ្ញាតពីក្រសួង?

៥. ដើម្បីពង្រឹងការអនុវត្តន៍ក្រមធនធានធម្មជាតិ និង បរិស្ថាន នៅក្នុងគន្ថីទី៧ ៖ **ការអប់រំ និងការយល់ដឹងអំពីបរិស្ថាន** គប្បីបញ្ចូលក្រសួងពាក់ព័ន្ធឲ្យធ្វើការផ្តល់វគ្គបណ្តុះបណ្តាលដល់អាជ្ញាធរមូលដ្ឋាន និងផ្សព្វផ្សាយដល់ប្រជាពលរដ្ឋជាភាសាសម្រាយងាយយល់ពីក្រមនេះ តាមរយៈ ទូរទស្សន៍ វិទ្យុ ឬ ប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ ឲ្យកាន់តែច្បាស់ដើម្បីភាពងាយស្រួលក្នុងការរួមគ្នាអនុវត្តន៍ក្រមនេះប្រកបដោយប្រសិទ្ធិភាព និង ប្រសិទ្ធិផល។ តម្រូវការកញ្ចប់ថវិកាពីថ្នាក់ជាតិ ឬពីប្រភពជំនួយផ្សេងៗចំពោះការអនុវត្តន៍វគ្គបណ្តុះបណ្តាលនេះ គឺចាំបាច់ដាក់បញ្ចូលក្នុងក្រមនេះ ដើម្បីធានាថាមានការ ការពារបរិស្ថាន និងគ្រប់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។

៦. ស្នើឲ្យបញ្ចូលគោលការណ៍សិទ្ធិមនុស្សដើម្បីការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព ជាពិសេស **គោលការណ៍អង្គការសហប្រជាជាតិណែនាំស្តីពីធុរកិច្ចនិងសិទ្ធិមនុស្ស** (UN Guiding Principles on Business and Human Rights), **សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីសិទ្ធិជនជាតិដើមភាគតិច** (UNDRIP), **ការយល់ព្រមជាមុន ដោយសេរី បន្ទាប់ពីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយសម្រាប់ជនជាតិដើមភាគតិច** (FPIC), **អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ** (CEDAW) ព្រមទាំងច្បាប់អន្តរជាតិ និង/ឬ កត្តិការសញ្ញា ឬ អនុសញ្ញាអន្តរជាតិពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានធម្មជាតិនានាដែលកម្ពុជាបានចុះហត្ថលេខាជាប្រទេសហត្ថលេខី។ ឧទាហរណ៍៖

មាតិកាទី៣៖ **ការចូលរួមជាសាធារណៈ** គួរបង្ហាញពីសិទ្ធស្របច្បាប់របស់ប្រជាពលរដ្ឋ ក្នុងការចូលរួមសម្រេចចិត្តទាក់ទងនឹងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ជាពិសេសការចូលរួមសម្រេចចិត្តរបស់ក្រុមជនជាតិដើមភាគតិច និង ជនជាតិខ្មែរដែលរស់នៅតំបន់អភិវឌ្ឍន៍គម្រោង។

៧. **ការពន្យល់វាក្យស័ព្ទ** និង ការប្រើវាក្យស័ព្ទ គប្បីឲ្យស្របគ្នាទៅនឹងបរិបទប្រទេសកម្ពុជា។ ឧទាហរណ៍៖ មាននិយមន័យនៃពាក្យ«ទឹកក្រោមដី» «ទឹកលើដី» និង «ទឹក» នៅក្នុងផ្នែក ការគ្រប់គ្រងធនធានទឹកដោយនិរន្តរភាព និង ការត្រួតពិនិត្យការបំពុលទឹក គឺមិនច្បាស់ថាតើនឹងសំដៅទៅលើការប្រើប្រាស់ និយមន័យនៃ«ទឹក»មួយណា។ ពាក្យខ្លះត្រូវត្រួតពិនិត្យឡើងវិញ និងខ្លះទៀតត្រូវលុបចោល ឬ បន្ថែម។ ឧទាហរណ៍ ពាក្យ «ដៃតាប៉េស» គួរប្តូរមក «ទិន្នន័យមូលដ្ឋាន» «ការគ្រប់គ្រងកាកសំណល់ជាតិពុល» «ពិន័យអន្តរការ»ជាលុយកាក់) ឬ ទោសទណ្ឌ( គឺមិនទាន់មានការពន្យល់ឲ្យបានច្បាស់លាស់។

៨. គប្បីបញ្ចូល ការពន្យល់ឲ្យស្របនឹងបរិបទប្រទេសកម្ពុជា ព្រមទាំងច្បាប់ដែលពាក់ព័ន្ធ ទាក់ទងនឹង **ការគ្រប់គ្រងតំបន់ឆ្នេរ ការគ្រប់គ្រងព្រៃឈើ ការគ្រប់គ្រងធនធានជលផលទាំងទឹកសាប និង ទឹកប្រៃ និង វារីវប្បកម្ម** ព្រោះការបរិយាយនៅក្នុងសេចក្តីព្រាងក្រម ភាគច្រើនគឺសរសេរជាលក្ខណៈបរិបទបរទេស គប្បីពិនិត្យបន្ថែមលើ ច្បាប់ អនុក្រិត សន្ធិសញ្ញា ឬ កតិកាសញ្ញា ផ្សេងៗ និង/ឬ កិច្ចព្រមព្រៀងទ្វេរភាគីនៃប្រទេសជាប់ព្រំដែន ដែលពាក់ព័ន្ធ ដើម្បីធានាពីដែនអធិបតេយ្យភាពនៃតំបន់ឆ្នេរក្នុងប្រទេសកម្ពុជា និង ដើម្បីឲ្យការគ្រប់គ្រងធនធានព្រៃឈើ ជលផល អនុលោមតាមច្បាប់ដែលមានស្រាប់។ ស្នើឲ្យសសេរឃ្លាលំអិតឲ្យច្បាស់ បន្ថែមជំពូក និង មាត្រាដែលពាក់ព័ន្ធ ដោយប្រើច្បាប់ ឬ លក្ខខណ្ឌគតិយុត្តិ ៤ ផ្សេងៗរបស់ប្រទេសកម្ពុជា។

៩. ពិចារណាអំពីការបញ្ចូល **ការទទួលខុសត្រូវសង្គមរបស់សារជីវកម្ម** CSR (Corporate Social Responsibility) និង **ការបង់ថ្លៃសេវាកម្មប្រព័ន្ធអេកូឡូស៊ី** (Payment for Ecosystem Service) ដើម្បីធានានិរន្តរភាពក្នុងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ព្រមទាំងការគោរពលើគោលការណ៍សិទ្ធិមនុស្សអន្តរជាតិ (UN Guiding Principles on Business and Human Rights) ។ គួរមានជាអនុក្រិត ឬ សេចក្តីណែនាំ ពីការកំណត់ឲ្យជាក់លាក់នៃកំរៃសេវាដែលត្រូវបង់ផ្អែកតាមប្រភេទអាជីវកម្ម។

១០. ទាក់ទងនឹងការ **គ្រប់គ្រងធនធានទឹកប្រកបដោយនិរន្តរភាព** គួរបញ្ចូល៖

ក. ការត្រួតពិនិត្យគុណភាពទឹកទាំងលើដី និង ក្រោមដី៖ ក្រម គួរតែកំណត់កម្មវិធីតាមដានត្រួតពិនិត្យគុណភាពទឹកក្រោមដី និងលើផ្ទៃដី ជាក់លាក់ជារួមមួយ ឬគួរតម្រូវឱ្យក្រសួងធនធានទឹកនិងឧតុនិយមសហការជាមួយក្រសួងពាក់ព័ន្ធដទៃទៀត ដើម្បីបង្កើតកម្មវិធីតាមដានត្រួតពិនិត្យនេះតាមរយៈការអនុវត្តតាមអនុក្រឹត្យ។ កម្មវិធីតាមដានត្រួតពិនិត្យនេះ គួរតែកំណត់យ៉ាងច្បាស់ថាមានការរាយការណ៍លើទិន្នន័យគុណភាពទឹកទៅដល់ក្រសួងធនធានទឹក និងឧតុនិយម សមភាគីថ្នាក់ក្រោមជាតិរបស់ខ្លួន និងគណៈកម្មការអាងទន្លេពាក់ព័ន្ធ។ ការបង្កើតកម្មវិធីតាមដានត្រួតពិនិត្យគុណភាពទឹកក្រោមដី និង លើដី ជារួម នេះគឺអាចជាគម្រូមួយសម្រាប់ការអនុវត្ត ផ្នែកផ្សេងទៀតនៃក្រមប្រកបដោយប្រសិទ្ធិភាព។ លើសពីនេះទៀតកម្មវិធីតាមដានត្រួតពិនិត្យគុណភាពទឹកនេះ គួរតែអនុញ្ញាតឱ្យមានការចូលរួមពីសាធារណៈជនដើម្បីបញ្ចូលព័ត៌មានឱ្យបានច្រើនបំផុតដែលអាចធ្វើទៅបាន។

ខ. ការទាញយកទឹកក្រោមដីប្រើហួសប្រមាណ៖ កូដគួរសរសេរឲ្យជាក់លាក់បន្ថែមទាក់ទងនឹងការទាញយកទឹកក្រោមដីប្រើហួសប្រមាណ ឧទាហរណ៍៖ បទប្បញ្ញត្តិស្ដីពីការអភិវឌ្ឍផែនការយុទ្ធសាស្ត្រជាតិធនធានទឹក គួរតម្រូវឱ្យមានផែនការ គោលបំណង និងការវាស់វែងជាក់លាក់ដើម្បីកំណត់ថាតើបរិមាណប៉ុន្មានដែលបញ្ជាក់ថាប្រើហួសប្រមាណ ហើយបរិមាណប៉ុន្មានដែលប្រើត្រឹមត្រូវតាមស្តង់ដា។ លើសពីនេះទៅទៀត ផែនការធនធានទឹកអាងទន្លេ គួរតែត្រូវបានបញ្ជាក់ឲ្យច្បាស់ថា បរិមាណទឹកទន្លេប៉ុន្មានដែលតម្រូវឱ្យមានក្នុងទន្លេដើម្បីជៀសវាងការប៉ះពាល់បរិមាណ និង គុណភាពទឹកក្រោមដី (គន្លីទី៤ មាតិកា៩ ជំពូកទី៣ ផ្នែកទី ៣ មាត្រាទី ២៨) ។

គ. ការគ្រប់គ្រងទឹកជំនន់ និង គ្រោះរាំងស្ងួត៖ ទឹកជំនន់ និង គ្រោះរាំងស្ងួត អាចជះផលប៉ះពាល់ និង បំផ្លិចបំផ្លាញលើជីវភាពរស់នៅ និងប្រព័ន្ធអេកូឡូស៊ី។ ក្រមគួរតែតម្រូវឱ្យមាន ផែនការជាតិគ្រប់គ្រងធនធានទឹក និង ផែនការគ្រប់គ្រងអាងទន្លេ ដើម្បីរួមបញ្ចូលគ្នាបង្កើតជាយុទ្ធសាស្ត្រគ្រប់គ្រងទឹកជំនន់ និង គ្រោះរាំងស្ងួត។

ឃ. បញ្ហាផ្សេងៗ៖ ក្រមនេះគួរមានបទប្បញ្ញត្តិច្បាស់លាស់និងស្តង់ដាជាក់លាក់ដើម្បីទប់ស្កាត់ការបំពុលពីតំបន់រោងចក្រ ការជីកយករ៉ែ ទឹកបំពុលពីគេហដ្ឋាន បរិមាណទឹកសម្រាប់ស្រោចស្រព ព្រមទាំងពិចារណាលើ លំហូរបរិស្ថាន បញ្ហាទឹកឆ្លងដែន (Transboundary issue) ។ ករណីដូចជា ទីក្រុងដែលមាននិរន្តរភាព គួរពិចារណាពី ទំហំកន្លែងស្តុកទឹកស្អុយ បរិមាណលំហូរទឹកស្អុយសារធាតុពុលដែលមានក្នុងទឹកស្អុយដូចជា សំណល់រាវ ឬ សំណល់រឹងពី មន្ទីរពេទ្យ រោងចក្រ អាគារធំៗ

១១. ការបញ្ចូលបរិបទ ការប្រែប្រួលអាកាសធាតុ គឺមិនទាន់រៀបចំតាមលំដាប់លំដោយ និងមានឃ្លាលំអិត និងគប្បីបន្ថែមជំពូក និង មាត្រា មួយចំនួនទៀត ដើម្បីធានាថាព្រះរាជាណាចក្រកម្ពុជា ក៏មានវិធានការក្នុងការការពារធនធានធម្មជាតិ និងបរិស្ថាន ស្របពេលជាមួយនឹងបរិបទសកលលោកដែលបានចាត់ ទុកបញ្ហាការប្រែប្រួលអាកាសធាតុ ជាបញ្ហារួមរបស់ពិភពលោក។ កត្តិការសញ្ញា ឬ អនុសញ្ញាអន្តរជាតិ ឬ កិច្ចព្រមព្រៀងអន្តរជាតិនានាដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុគួរគប្បីដាក់បញ្ចូលក្នុងក្រមនេះ ដូចជា យន្តការរ៉េតបូក(REDD+) និង យន្តការអភិវឌ្ឍន៍ស្អាត (CDM)។ ជាងនេះទៀត ក្រមគួរតែតម្រូវឲ្យមានការបញ្ចូលការវិភាគពីការប្រែប្រួលអាកាសធាតុ ក្នុងការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង ដំណើរការនៃការគ្រប់គ្រងធនធានធម្មជាតិ។ ឧទាហរណ៍៖ បញ្ហាការប្រែប្រួលអាកាសធាតុក្នុងការរៀបចំបង្កើត ផែនការយុទ្ធសាស្ត្រជាតិស្តីពីការគ្រប់គ្រងធនធានទឹក និង អាងទន្លេ នៃព្រះរាជាណាចក្រកម្ពុជា។

១២. ក្រមគួរតែតម្រូវឲ្យក្រសួងពាក់ព័ន្ធនីមួយៗបង្កើត ផែនការយុទ្ធសាស្ត្រ និង ផែនការសកម្មភាពលើការគ្រប់គ្រងគ្រោះមហន្តរាយ និង/ឬ ហានិភ័យផ្សេងទៀតដែលបង្កឡើងតាមរយៈការប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍ដូចជា កំណត់បរិមាណជាក់លាក់នៃការប្រើថង់ប្លាស្ទិកដែលមិនសូវបំពុលខ្លាំងទៅដល់បរិស្ថាន។

១៣. ផែនការគ្រប់គ្រងគ្រោះមហន្តរាយ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងបច្ចេកវិទ្យាបន្ធូរបន្ថយការបំភាយឧស្ម័នក្នុងបរិយាកាស (mitigation technologies) គួរពិចារណាដាក់បញ្ចូលក្នុងក្រមនេះ ដោយមានការបរិយាយច្បាស់លាស់ពីប្រភពថវិកាគ្រប់គ្រាន់ សម្រាប់ការអនុវត្តផែនការទាំងនេះ

១៤. ដើម្បីធានាការប្រើប្រាស់**ថាមពលប្រកបដោយនិរន្តរភាព**ក្នុងប្រទេស និង គោរពតាមគោលការណ៍សិទ្ធមនុស្សអន្តរជាតិ ព្រមទាំងកាត់បន្ថយការបំពុលបរិស្ថានមកកម្រិតអប្បរមា ក្រមគួរបញ្ចូល

៖ (១)ស្វែងរកថាមពលកកើតឡើងវិញដែលសមស្របនឹងបរិបទប្រទេសកម្ពុជា (២) ស្តង់ដាប្រសិទ្ធិភាពថាមពលទាំងការផលិត និង ការប្រើប្រាស់ (គួរមានស្ថាប័នដើម្បីត្រួតពិនិត្យគុណភាពឧបករណ៍ថាមពលដែលនាំចូល ត្រួតពិនិត្យស្តង់ដាផលិតថាមពលនៃអាជីវកម្មចែកចាយបន្ត និងគួរមានការទិញថាមពលពីប្រជាពលរដ្ឋវិញបើគាត់ប្រើមិនអស់ និងគួរកំណត់ពីតម្លៃអគ្គិសនីផ្សេងគ្នារវាងតំបន់ទីប្រជុំជន និង តំបន់ជនបទ) និង(៣) គួរមានការកំណត់ឲ្យច្បាស់លាស់ពីគោលដៅនៃការកែច្នៃឡើងវិញនៃឧបករណ៍ផលិតថាមពល (goals for recycling energy material) ។ ការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីខ្នាតធំ ពិសេស នៅលើតួទន្លេមេនៃទន្លេមេគង្គ គួរគប្បីពិចារណាឲ្យបានគ្រប់ជ្រុងជ្រោយ ព្រោះវាអាចធ្វើឲ្យប៉ះពាល់ខ្លាំងដល់មច្ឆាជាតិក្នុងបឹងទន្លេសាប ដែលជាប្រភពចំណូលយ៉ាងចម្បងរបស់ប្រជាពលរដ្ឋកម្ពុជា។ ការអភិវឌ្ឍន៍ថាមពលនុយក្លេអែរ គួរធ្វើការពិចារណាឲ្យបានម៉ត់ចត់ជាទីបំផុត ថាតើគួរតែដាក់បញ្ចូលក្នុងក្រម ឬ ដកចេញ ព្រោះវាជាប្រភពថាមពលមួយដែលគ្រោះថ្នាក់ជាទីបំផុត ប្រសិនបើយើងគ្មានធនធានមនុស្ស និង ធនធានថវិកាគ្រប់គ្រាន់ដើម្បីធ្វើការគ្រប់គ្រងនោះទេ។

១៥. ជាទូទៅសេចក្តីព្រាងក្រមធនធានធម្មជាតិ និងបរិស្ថាន ក្នុងមាតិការទី៧ **ឧស្សាហកម្មនិស្សារណកម្មប្រកបដោយការទទួលខុសត្រូវ** បានកំណត់យ៉ាងល្អទៅលើចំណុច ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សវនៈកម្ម បរិស្ថាន ផែនការបរិស្ថាន របាយការណ៍និងស្តង់ដាបរិស្ថាន និងផែនការសង្គ្រោះបន្ទាន់។ ទន្ទឹមនេះ ក្រមបរិស្ថាន គួរបញ្ចូលផែនទីច្បាស់លាស់ដើម្បីកំណត់តំបន់ណាដែលទុកសម្រាប់អភិវឌ្ឍន៍វិស័យនេះ និងតំបន់ណាទុកសម្រាប់អភិរក្ស ដើម្បីជៀសវាងការបំពុលធ្ងន់ធ្ងរដែលមិនអាចស្រោចស្រង់បាន។ ជាងនេះទៅទៀត ក្រមបរិស្ថានគួរពិចារណាលទ្ធភាពក្នុងការដាក់បញ្ចូល យន្តការដោះស្រាយជម្លោះ ការរួមបញ្ចូលសហគមន៍ជនជាតិដើមភាគតិច ជាពិសេសស្ត្រី ក្នុងដំណើរការណ៍រៀបចំគម្រោង និងការសម្រេចចិត្តលើគម្រោងឧស្សាហកម្មនិស្សារណកម្ម។

១៦. គប្បីបញ្ចូល **និរន្តរភាព តំបន់ដីសើម និងរ៉ាមសារ** (Wetland/Ramsar) ពីព្រោះប្រទេសកម្ពុជាមានតំបន់នេះជាច្រើនកន្លែងដូចជា នៅខេត្តស្ទឹងត្រែង ខេត្តកំពង់ធំ ខេត្តកំពត -ល- ដែលមានតួនាទីសំខាន់ក្នុងការ ផ្តល់ជាជម្រក និង ចំនី ដល់ជីវចម្រុះទាំងលើគោក និង ក្នុងទឹក ជាពិសេសដើម្បីធានធានិរន្តរភាពនៃ គ្រប់គ្រងធនធានធម្មជាតិក្នុងប្រទេសកម្ពុជា តំបន់ដីសើម និងរ៉ាមសារ គឺចាំបាច់ត្រូវតែមានការ ការពារ អភិរក្ស និង ថែរក្សា។ ក្រមគួរតែតម្រូវឲ្យ ក្រសួងបរិស្ថាន ធ្វើការជាមួយក្រសួងដែលពាក់ព័ន្ធ ក្នុងការបង្កើតអនុក្រិតការពារតំបន់នេះដើម្បីជៀសវាងការបាត់បង់ និង ការបំផ្លិចបំផ្លាញតំបន់នេះ។

១៧. គប្បីបន្ថែមចំនុច **ការចុះបញ្ជីដីសហគមន៍** នៅក្នុង តំបន់ការពារសហគមន៍ (Community Protected Area) ដើម្បីធានាថា សហគមន៍មានសិទ្ធិក្នុងការប្រើប្រាស់ដីជាលក្ខណៈសមូហភាពជាមួយសហគមន៍របស់ពួកគេ។

១៨. គប្បីបញ្ចូល អង្គការសង្គមស៊ីវិល និង សហគមន៍ ជា គណៈកម្មការមូលនិធិបរិស្ថាន

១៩. គណៈកម្មការ សន្ទានកម្មបរិស្ថាន ត្រូវបញ្ចូលក្រុមយុវជន។

២០. ការគ្រប់គ្រងសំណល់ដែលមានគ្រោះថ្នាក់ គួរបន្ថយថ្លៃសម្រាប់ក្រុមហ៊ុនធ្វើការគ្រប់គ្រងសំណល់កុំទុករយៈពេលយូរពេក ព្រោះអាចបណ្តាលឲ្យមានគ្រោះថ្នាក់ខ្លាំង។ ឧទាហរណ៍ ដូចជា សំណល់វិទ្យុសកម្ម សំណល់ដែលមានសារធាតុគីមីពុល។

២១. ការគ្រប់គ្រងការដឹកជញ្ជូនផលិតផលនាំចូល ដែលមានសារធាតុពុល គីមី គប្បីមានការត្រួតពិនិត្យឲ្យបានម៉ត់ចត់ជាទីបំផុត ដើម្បីជៀសវាងការសាយភាយការបំពុលទៅដល់ប្រជាពលរដ្ឋ និងបរិស្ថានជុំវិញ។

២២. ស្តង់ដា នៃកម្រិតសារធាតុពុល សារធាតុវិទ្យុសកម្ម សារធាតុបំពុលគីមីផ្សេងៗ ដែលបង្ហូរចូលក្នុងទឹកសាប ឬ ទឹកសមុទ្រ ឬ លើដី គួរកំណត់ ឬ បញ្ជាក់ការយោងពី អនុក្រិត ឬ គោលការណ៍ណែនាំជាក់លាក់ណាមួយដែលកំណត់ពីស្តង់ដា ឬ សុចករនៃសារធាតុបំពុល ឬសារធាតុគីមីផ្សេងៗ ។ល។ ដែលអនុញ្ញាតិដោយច្បាប់ក្នុងន័យដើម្បីឲ្យ ប្រជាពលរដ្ឋ ក៏ដូចជា អង្គការសង្គមស៊ីវិល ស្ថាប័នស្រាវជ្រាវ មានភាពងាយស្រួលក្នុងការទៅរក អនុក្រិត ឬ គោលការណ៍ណែនាំលម្អិតនោះ។

២៣. ទោសទណ្ឌក្នុងការចូលរួមធ្វើឲ្យខូចបរិស្ថាន ត្រូវពិន័យតាមផ្នែករដ្ឋបាល និង/ឬ បញ្ឈប់ពីការងារជា ផ្លូវការ។

២៤. ការអនុវត្តក្រមធនធានធម្មជាតិ និងបរិស្ថានក្រកបដោយតម្លាភាព និងប្រសិទ្ធភាព

២៥. ធានាថាមានធនធាន និងថវិការសំរាប់គាំទ្រ អនុវត្តក្រមធនធានធម្មជាតិ និងបរិស្ថាននេះ

២៦. ស្នើរអោយយកសេចក្តីព្រាងច្បាបើស្តីពីការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដាក់បញ្ចូលទាំងស្រុងទៅក្នុងសេចក្តីព្រាងចុងក្រោយនៃក្រមធនធានធម្មជាតិ និងបរិស្ថាន